**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ៣០៥១ ព.ណ.សរ.

ថ្ងៃព្រហស្បតិ៍ ៧កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅឲ្យបានជ្រាបថា៖ ដើម្បីជំរុញសកម្មភាពពាណិជ្ជកម្មក្នុងស្រុក ឲ្យមានភាពរស់រវើក និងឲ្យកាន់តែប្រសើរឡើងនូវការទទួលស្គាល់ផលិតផលបន្លែ ផ្លែឈើខ្មែរ និងកសិផលកែច្នៃដទៃទៀត ស្របតាមយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការលើកកម្ពស់វិស័យកសិ-ពាណិជ្ជកម្ម និងអភិវឌ្ឍន៍វិស័យឯកជន ក្រសួងពាណិជ្ជកម្ម នឹងរៀបចំដាក់តាំងបង្ហាញផលិតផលបន្លែ ផ្លែឈើខ្មែរ និងផលិតផលកែច្នៃដទៃទៀតលើកទី១៣ ឆ្នាំ២០២០ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២១-២៤ ខែវិច្ឆិកា ឆ្នាំ២០២០ នៅក្រុងសៀមរាប ខេត្តសៀមរាប។

ការរៀបចំព្រឹត្តិការណ៍នេះ ក្នុងគោលបំណងបង្កើនសម្មភាពពាណិជ្ជកម្មនៅមូលដ្ឋាន ឲ្យមានភាពប្រទាក់ក្រឡាពីកសិដ្ឋានមកទីផ្សារ និងទាក់ទាញចំណាប់អារម្មណ៍របស់ប្រតិបត្តិករអាជីវកម្ម និងមហាជនទូទៅឲ្យងាកមកគាំទ្រ និងចូលរួមប្រើប្រាស់ផលិតផលក្នុងស្រុកជំនួសឲ្យការនាំចូលពីបរទេសជាជំហានៗ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្មសូមអញ្ជើញ លោក-លោកស្រី ពាណិជ្ជករ សេវាករ និងសាធារណជនទូទៅ ចូលរួមទស្សនា និងគាំទ្រព្រឹត្តិការណ៍ដ៏ពិសេសនេះកុំបីខាន។

ចំពោះម្ចាស់កសិដ្ឋាន អ្នកកែច្នៃ សមាគមអាជីវកម្ម និងសហគមន៍ផលិតបន្លែ និងផ្លែឈើខ្មែរ ដែលត្រូវការស្តង់ដាក់តាំងផលិតផលសម្រាប់ស្វែងរកដៃគូបញ្ជាទិញ ឬមានគម្រោងចុះកិច្ចសន្យាទិញ-លក់ សូមទាក់ទងអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំងស្ថិតនៅជាន់ទីពីរនៃអគារ ទីស្តីការក្រសួងពាណិជ្ជកម្មអាសយដ្ឋានៈដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០១២ ៩៤០ ៦០៦ ឬ ០១២ ៨៥៣ ៨៤៨ ឬ ០៩៨ ៨១៨ ១៤៨

អាសយដ្ឋានអ៊ីម៉ែល៖ somsothearith0606gmail.com ឬ soknea.kh@gmail.com

ទាក់ទងមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប៖ ទូរស័ព្ទលេខ ០១២ ៩៦៦ ៤៦៦ / ០១២ ៥៥០ ៦៣៥

អាសយដ្ឋានអ៊ីម៉ែល៖ kimly@gmail.com

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

នាយកដ្ឋានកិច្ចការពិព័រណ៍

# ពាក្យសុំចុះឈ្មោះ

## ចូលរួមពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ

## ពិធីតាំងបង្ហាញផលិតផលបន្លែ និងផ្លែឈើ លើកទី១៣ ឆ្នាំ២០២០

នៅខេត្តសៀមរាប ចាប់ពីថ្ងៃ២១-២៤ ខែវិច្ឆិកា ឆ្នាំ២០២០

### ១.ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | |
| ឈ្មោះប្រធានក្រុមហ៊ុន | |
| អាសយដ្ឋានក្រុមហ៊ុន | |
| ទូរស័ព្ទ ឬទូរសារ | |
| អ៊ីមែល | |

### ២.ព័ត៌មានអំពីប្រភេទផលិតផលដែលត្រូវចូលរួមដាក់តាំងបង្ហាញ

| ប្រភេទផលិតផល | | រាយមុខផលិតផល |
|---|---|---|
| កសិផល | ☐ | |
| ជលផល | ☐ | |
| ផលិតផលម្ហូបអាហារ | ☐ | |
| ផលិតផលកេសជ្ជៈ | ☐ | |
| ផលិតផលសិប្បកម្ម | ☐ | |
| ផលិតផលឧស្សាហកម្ម | ☐ | |
| គ្រឿងសង្ហារិម | ☐ | |
| សេវាកម្ម | ☐ | |

### ៣-លក្ខខណ្ឌនៃការចូលរួម

-ត្រូវរៀបចំស្តង់របស់ខ្លួនឲ្យបានរួចរាល់មុន០១ថ្ងៃ នៃថ្ងៃបើកសម្ពោធពិព័រណ៍

-មិនអនុញ្ញាត ឲ្យលក់ផលិតផលផ្សេងៗដែលមិនមានបំពេញនៅក្នុងបែបបទខាងលើ

-មិនអនុញ្ញាត ឲ្យផ្ទេរស្តង់ ឬក៏ទុកស្តង់នៅទំនេរក្នុងរយៈពេលនៃការតាំងពិព័រណ៍

ក្នុងករណីមិនបានអនុវត្តន៍ ដូចបានជម្រាបជូនខាងលើ គណៈកម្មការរៀបចំពិព័រណ៍មានសិទ្ធិបិទស្តង់ ឬដកហូតស្តង់មកវិញ ហើយរាល់ការចំណាយសាងសង់ស្តង់ជាបន្ទុករបស់ម្ចាស់ស្តង់។

ខ្ញុំបាទ/នាងខ្ញុំ ជាប្រធាន/តំណាងក្រុមហ៊ុន សូមធានាអះអាង និងគោរពតាមការណែនាំ និងបំពេញតាមលក្ខខណ្ឌតម្រូវរបស់គណៈកម្មការ។ បើខុសពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ប្រធាន/តំណាងក្រុមហ៊ុន**

ហត្ថលេខា/ត្រា

**សម្រាប់មន្ត្រី**

- លេខ៖.................................
- ថ្ងៃ ខែ ឆ្នាំ៖.....................ម៉ោង.....................
- អ្នកទទួល៖.................................